## ការវាយប្រហារទូទៅ និងជាប្រព័ន្ធ (widespread and systematic attack)

មិនមែនគ្រប់បទល្មើសប្រព្រឹត្តិ សុទ្ធតែអាចត្រូវបានចាត់ជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ (crime against humanity)។ ដើម្បីចាត់ជាបទឧក្រិដ្ឋប្រភេទនេះ ទង្វើត្រូវតែ ជាផ្នែកមួយនៃការវាយប្រហារជាទូទៅ (attack)។ ទាញចេញពីនេះ ការប្រព្រឹត្តសកម្មភាព ជាលទ្ធផល បន្ថែមលើការវាយប្រហារ និង ជនល្មើសដឹងថាមានការវាយប្រហារលើជនស៊ីវិល (civilian)។

មិនមានការទាមទារថា ជនល្មើសត្រូវតែប្រព្រឹត្តបទល្មើសច្រើនទេ (series of crime)។ សកម្មភាពតែមួយអាចគ្រប់គ្រាន់ឲ្យតែជាផ្នែកនៃការវាយប្រហារ។ ដូចគ្នានេះដែរ ទង្វើ មិនចាំបាច់ ស្របពេលនឹងការវាយប្រហារដទៃទៀត វាអាចកើតមុនឬក្រោយ។ អ្វីសំខាន់គឺមានចំណងទាក់ទងគ្រប់គ្រាន់ (causation)។ ដូចនេះ សកម្មភាពដោយឡែក (isolated act) មិនត្រូវបានរាប់បញ្ចូលទេ។

តុលាការ ត្រូវពិចារណានូវកាលៈទេសៈទាំងអស់ ដូចជាប្រភេទ គោលបំណង ផលវិបាកនៃទង្វើ។ នេះជាបន្ទុករបស់រដ្ឋអាជ្ញា ក្នុងការបង្ហាញហួសពីវិមតិសង្ស័យ (beyond reasonable doubt) ថាបទល្មើសត្រូវបានប្រព្រឹត្តឡើង (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p. 436)។